ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន

លេខៈ ៣៥៩១ ប្រក.ប.ស្ត /៧ហប /០៥២៩

# ប្រកាស
# ស្តីពី
# ចំណាត់ថ្នាក់គម្រោងអភិវឌ្ឍសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២៣/០០៧ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើក្រមបរិស្ថាននិងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងបរិស្ថាន



អគារមរតកតេជោ ដីឡូតិ៍លេខ503 ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: 023 235 004 / 023 235 006

## សម្រេច

**ប្រការ១.-**

ប្រកាសនេះកំណត់ការធ្វើចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សម្រាប់គម្រោងអភិវឌ្ឍ ដែលតម្រូវឱ្យរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬកិច្ចសន្យាការពារបរិស្ថាន ដើម្បីជួយសម្រួល និងផ្តល់ការណែនាំដល់ម្ចាស់គម្រោងអភិវឌ្ឍ ក្នុងការអនុវត្តនូវនីតិវិធីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សម្រាប់គម្រោងអភិវឌ្ឍឱ្យមានប្រសិទ្ធភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះប្រភេទគម្រោងអភិវឌ្ឍដែលបានស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់និងកំពុងដំណើរការរបស់បុគ្គលឯកជន ក្រុមហ៊ុនឯកជន ក្រុមហ៊ុនចម្រុះរដ្ឋ ឬក្រុមហ៊ុនរដ្ឋ ក្រសួង-ស្ថាប័នរដ្ឋ ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១-**គម្រោងអភិវឌ្ឍ៖** សំដៅលើគម្រោងវិនិយោគទាំងសាធារណៈ និងឯកជន មានជាអាទិ៍ គម្រោងស្នើសុំ គម្រោងមានស្រាប់ និងគម្រោងកំពុងដំណើរការ។

២-**ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន៖** សំដៅដល់ការសិក្សាលើធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ ធនធានសេដ្ឋកិច្ចសង្គម និងសម្បត្តិវប្បធម៌ ហើយភាគច្រើនពឹងផ្អែកលើទិន្នន័យមានស្រាប់ឬទិន្នន័យចម្បងដែលនៅក្នុង និងជុំវិញតំបន់គម្រោង ដើម្បីជាមូលដ្ឋានក្នុងការកំណត់ ព្យាករណ៍ និងការវិភាគនូវសក្តានុពលហេតុប៉ះពាល់បរិស្ថាននិងសង្គម ដែលអាចកើតមានឡើងដោយសារសកម្មភាពគម្រោង ដើម្បីរកវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមានឱ្យដល់កម្រិតអប្បបរមា និងបង្កើតហេតុប៉ះពាល់បរិស្ថានវិជ្ជមានឱ្យដល់កម្រិតអតិបរមា។

៣-**រោងចក្រ៖** សំដៅដល់សហគ្រាសកម្មន្តសាល ដែលមាន ឬរំពឹងថានឹងមានឧបករណ៍ ម៉ាស៊ីន សម្ភារៈ និងបរិក្ខារ ដែលត្រូវប្រើនៅក្នុងសហគ្រាស ដើម្បីផលិតផលិតផល ដែលមានទុនសមមូលសរុបច្រើនជាង ៥០០ ០០០(ប្រាំរយពាន់) ដុល្លារអាមេរិក។

៤-**សហគ្រាសធុនមធ្យម៖** សំដៅដល់សហគ្រាសកម្មន្តសាល ដែលមាន ឬរំពឹងថានឹងមានឧបករណ៍ ម៉ាស៊ីន និងបរិក្ខារ ដែលត្រូវប្រើនៅក្នុងសហគ្រាស ដើម្បីផលិតផលិតផល ដែលមានទុនសមមូលសរុបចន្លោះពី ២៥០ ០០០(ពីររយហាសិបពាន់) ទៅក្រោម ៥០០ ០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក។

៥-**សហគ្រាសធុនតូច៖** សំដៅដល់សហគ្រាសកម្មន្តសាល ដែលមាន ឬរំពឹងថានឹងមានឧបករណ៍ ម៉ាស៊ីន និងបរិក្ខារ ដែលត្រូវប្រើនៅក្នុងសហគ្រាស ដើម្បីផលិតផលិតផល ដែលមានទុនសមមូលសរុបចន្លោះពី ៥០ ០០០(ហាសិបពាន់) ទៅក្រោម ២៥០ ០០០(ពីររយហាសិបពាន់) ដុល្លារអាមេរិក។

៦-**សិប្បកម្ម៖** សំដៅដល់សហគ្រាសកម្មន្តសាលដែលមាន ឬពឹងផ្អែកលើការប្រើប្រាស់ឧបករណ៍ ម៉ាស៊ីន និងបរិក្ខារ ដែលត្រូវប្រើនៅក្នុងសិប្បកម្ម ដើម្បីផលិតផលិតផល ដែលមានទុនសមមូលតិចជាង ៥០ ០០០ (ហាសិបពាន់) ដុល្លារអាមេរិក។

**ប្រការ៤.-**

ប្រភេទគម្រោងអភិវឌ្ឍដែលតម្រូវឱ្យរៀបចំកិច្ចសន្យាការពារបរិស្ថាន គឺសំដៅដល់គម្រោងដែលមានការប៉ះពាល់តិចតួចដល់បរិស្ថាន និងសង្គម ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធ។ ករណីគម្រោងអភិវឌ្ឍមានការប៉ះពាល់មធ្យម ឬធ្ងន់ធ្ងរដល់បរិស្ថាន និងសង្គម នោះក្រសួងបរិស្ថានតម្រូវឱ្យម្ចាស់គម្រោងត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ។

ចំពោះគម្រោងអភិវឌ្ឍដែលតម្រូវឱ្យរៀបចំកិច្ចសន្យាការពារបរិស្ថាន ម្ចាស់គម្រោងត្រូវភ្ជាប់មកជាមួយនូវផែនការគ្រប់គ្រងបរិស្ថាន។

**ប្រការ៥.-**

ប្រភេទគម្រោងអភិវឌ្ឍដែលតម្រូវឱ្យរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង គឺសំដៅដល់គម្រោងដែលមានការប៉ះពាល់មធ្យមដល់បរិស្ថាន និងសង្គម ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធ។ ករណីគម្រោងអភិវឌ្ឍមានការប៉ះពាល់តិចតួច ឬធ្ងន់ធ្ងរដល់បរិស្ថាន និងសង្គម នោះក្រសួងបរិស្ថានតម្រូវឱ្យម្ចាស់គម្រោងរៀបចំកិច្ចសន្យាការពារបរិស្ថាន ឬរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ។

**ប្រការ៦.-**

ប្រភេទគម្រោងអភិវឌ្ឍដែលតម្រូវឱ្យរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ គឺសំដៅដល់គម្រោងដែលមានការប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន និងសង្គម ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធ។ ករណីគម្រោងអភិវឌ្ឍមានការប៉ះពាល់មធ្យម ឬតិចតួចដល់បរិស្ថាន និងសង្គម នោះក្រសួងបរិស្ថានតម្រូវឱ្យម្ចាស់គម្រោងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរៀបចំកិច្ចសន្យាការពារបរិស្ថាន។

**ប្រការ៧.-**

រយៈពេលនៃការពិនិត្យ និងផ្តល់យោបល់លើកិច្ចសន្យាការពារបរិស្ថាន មានរយៈពេល ៣០(សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទដែលក្រសួងបរិស្ថានទទួលបានពាក្យសុំពិនិត្យលើកិច្ចសន្យាការពារបរិស្ថាន ផែនការគ្រប់គ្រងបរិស្ថាន និងឯកសារពាក់ព័ន្ធ។

**ប្រការ៨.-**

រយៈពេលនៃការពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង មានរយៈពេល ៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទដែលក្រសួងបរិស្ថានទទួលបានរបាយការណ៍។ រយៈពេល ៦០(ហុកសិប)ថ្ងៃនេះ ត្រូវអស់សុពលភាពនៅពេលដែលក្រសួងបរិស្ថានបានផ្តល់យោបល់ ទោះបីជាយោបល់នោះជាយោបល់បដិសេធ ឬឯកភាព ឬបង្គាប់ឱ្យមានការកែតម្រូវលើរបាយការណ៍ក៏ដោយ។

**ប្រការ៩.-**

រយៈពេលនៃការពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ មានរយៈពេល ៩០(កៅសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទដែលក្រសួងបរិស្ថានទទួលបាន

របាយការណ៍។ រយៈពេល ៩០(កៅសិប)ថ្ងៃនេះ ត្រូវអស់សុពលភាពនៅពេលដែលក្រសួងបរិស្ថានបានផ្តល់យោបល់ ទោះបីជាយោបល់នោះជាយោបល់បដិសេធ ឬឯកភាព ឬបង្គាប់ឱ្យមានការកែលើរបាយការណ៍ក៏ដោយ។

**ប្រការ១០.-**

ប្រភេទគម្រោងអភិវឌ្ឍដូចមានភ្ជាប់នៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសនេះ អាចកែប្រែបានតាមរយៈប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**ប្រការ១១.-**

ប្រកាសលេខ ០២១ ប្រក ប.ស្ក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ១២.-**

អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងគ្រប់អង្គភាពក្រោមឱវាទក្រសួងបរិស្ថាន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ អង្គារ ១០ កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែឧសភា ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

**អ៊ាង សុផល្លែត**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១២ (ដើម្បីអនុវត្ត)
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃប្រកាសលេខ ៣៤៩១/០២៥ ប្រក.ប.ស្ថ/វហប**

**ថ្ងៃ ព្រហស្បតិ៍ ១០កើត ខែ ពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨**

**ត្រូវនឹងថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ២០២៥**

## ស្តីពីចំណាត់ថ្នាក់គម្រោងអភិវឌ្ឍសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

| ល.រ | ប្រភេទគម្រោង | ចំណាត់ថ្នាក់គម្រោងអភិវឌ្ឍ សម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន | | |
|---|---|---|---|---|
| | | វ.ហ.ប.ព | វ.ហ.ប.ដ | កិច្ចសន្យាការពារបរិស្ថាន |
| **១. វិស័យរ៉ែ ថាមពល ឧស្សាហកម្ម** | | | | |
| ១ | ការស្វែងរុករកធនធានរ៉ែ និង/ឬប្រេងកាត និង/ឬឧស្ម័ន | | (គ្រប់ទំហំ) | |
| ២ | ការធ្វើឧស្សាហកម្មអាជីវកម្មធនធានរ៉ែ | (គ្រប់ទំហំ) | | |
| ៣ | ការធ្វើអាជីវកម្មរ៉ែប្រេងកាត និង/ឬឧស្ម័ន | (គ្រប់ទំហំ) | | |
| ៤ | ការធ្វើអាជីវកម្មរ៉ែ លើកលែងអាជីវកម្មរ៉ែសំណង់គ្រប់ប្រភេទ មានដូចជា ថ្មកំបោរ ថ្មម៉ាប ថ្មភក់ ថ្មបំបែក ថ្មបាយក្រៀម ក្រួស ខ្សាច់ ឡាតេរីត អាចម៍ដី ដីឥដ្ឋ ហ្វូស្វាត កៅឡាំង ក្វាត។ល។ | (គ្រប់ទំហំ) | | |
| ៥ | ការធ្វើអាជីវកម្មរ៉ែសំណង់គ្រប់ប្រភេទ មានដូចជា ថ្មកំបោរ ថ្មម៉ាប ថ្មភក់ ថ្មបំបែក ថ្មបាយក្រៀម ក្រួស ខ្សាច់ ឡាតេរីត អាចម៍ដី ដីឥដ្ឋ ហ្វូស្វាត កៅឡាំង ក្វាត។ល។ | ( >៤០ហិកតា) | (>១០-៤០ហិកតា) | (≤១០ហិកតា) |
| ៦ | ការធ្វើអាជីវកម្មសិប្បកម្មធនធានរ៉ែ | | | ≤ ១ហិកតា និងជម្រៅ ៥ម៉ែត្រ |
| ៧ | គម្រោងផលិត កែច្នៃតនភ័ណ្ឌ គ្រឿងអលង្ការ ឬគ្រឿងអលង្ការពាក់ព័ន្ធ | | (គ្រប់ទំហំ) | |
| ៨ | រោងចក្រកែច្នៃរ៉ែមានតម្លៃ | (គ្រប់ទំហំ) | | |
| ៩ | សហគ្រាសលាងសម្អាតរ៉ែ | (គ្រប់ទំហំ) | | |
| ១០ | រោងចក្រផលិតឧស្ម័ន | (គ្រប់ទំហំ) | | |
| ១១ | រោងចក្រចម្រាញ់ប្រេងកាត | (គ្រប់ទំហំ) | | |
| ១២ | រោងចក្រគីមីប្រេងកាត | (គ្រប់ទំហំ) | | |
| ១៣ | សំណង់បង្ហូរប្រេង និង/ឬឧស្ម័ន | (ប្រវែង≥២គ.ម) | | |
| ១៤ | កន្លែងផ្ទុកប្រេងឥន្ធនៈ និង/ឬឧស្ម័ន សម្រាប់ចែកចាយ ឬមណ្ឌលសន្និធិប្រេងឥន្ធនៈ និង/ឬឧស្ម័ន | (>១ 000 000លីត្រ) | (>១២០.000 - ១ 000 000លីត្រ) | |
| ១៥ | ស្ថានីយប្រេងឥន្ធនៈ និង/ឬឧស្ម័ន ប្រេងឥន្ធនៈ និង/ឬមណ្ឌលសន្និធិប្រេងឥន្ធនៈ និង/ឬឧស្ម័ន | | (>១២០ 000លីត្រ) | (≥២០ 000-១២០ 000លីត្រ) |
| ១៦ | រោងចក្រស៊ីម៉ងត៍ | (គ្រប់ទំហំ) | | |
| ១៧ | រោងចក្រវារីអគ្គិសនី | (>៥០មេហ្គាវ៉ាត់) | (≥១– ៥០មេហ្គាវ៉ាត់) | (<១មេហ្គាវ៉ាត់) |
| ១៨ | រោងចក្រអគ្គិសនី | (> ៥០មេហ្គាវ៉ាត់) | (≥៥-៥០មេហ្គាវ៉ាត់) | (<៥មេហ្គាវ៉ាត់) |
| ១៩ | រោងចក្រផលិតជីគីមី | (គ្រប់ទំហំ) | | |
| ២០ | រោងចក្រផលិតថ្នាំលាបគ្រប់ប្រភេទ | (គ្រប់ទំហំ) | | |

| | | | | |
|---|---|---|---|---|
| ២១ | រោងចក្រគីមី | (គ្រប់ទំហំ) | | |
| ២២ | រោងចក្រកែច្នៃលោហៈគ្រប់ប្រភេទ ដែកគោល លួសបន្លា សំណាញ់ | (≥ ៣០០តោន/ខែ) | | |
| ២៣ | រោងចក្រស្លលោហៈគ្រប់ប្រភេទ | (គ្រប់ទំហំ) | | |
| ២៤ | រោងចក្រផលិតដែក និងសម្ភារៈផ្សេងៗ | (គ្រប់ទំហំ) | | |
| ២៥ | រោងចក្រផលិតប្រេងម៉ាស៊ូតធម្មជាតិ | (គ្រប់ទំហំ) | | |
| ២៦ | រោងចក្រផលិតប្រេងអេតាណុល/មេតាណុល | (គ្រប់ទំហំ) | | |
| ២៧ | រោងចក្រចម្រាញ់ប្រេងខ្មៅពីសំបកកៅស៊ូកង់រថយន្តចាស់ៗ | (គ្រប់ទំហំ) | | |
| ២៨ | រោងចក្រផលិតអាគុយ និងថ្មពិល | (គ្រប់ទំហំ) | | |
| ២៩ | រោងចក្រផលិតស្រា ស្រាបៀរ អាល់កុល និងគ្រឿងស្រវឹងគ្រប់ប្រភេទ | (គ្រប់ទំហំ) | | |
| ៣០ | រោងចក្រផលិតបារី ថ្នាំជក់ | (គ្រប់ទំហំ) | | |
| ៣១ | រោងចក្រផលិតថ្មស្អុយ | (គ្រប់ទំហំ) | | |
| ៣២ | រោងចក្រផលិតខ្លាញ់គោ ប្រេងម៉ាស៊ីន | (គ្រប់ទំហំ) | | |
| ៣៣ | រោងចក្រផលិតក្រដាស | (គ្រប់ទំហំ) | | |
| ៣៤ | រោងចក្រផលិតម្សៅក្រដាស និងកែច្នៃក្រដាស | (គ្រប់ទំហំ) | | |
| ៣៥ | រោងចក្រសម្លាប់ស្បែក កែច្នៃស្បែក ធ្វើការស្បែកសត្វ | (គ្រប់ទំហំ) | | |
| ៣៦ | រោងចក្រផលិតជីសរីរាង្គ | | (គ្រប់ទំហំ) | |
| ៣៧ | រោងចក្រផលិតសម្ភារៈបរិក្ខារអគ្គិសនី និងអេឡិច-ត្រូនិចគ្រប់ប្រភេទ | | (គ្រប់ទំហំ) | |
| ៣៨ | គម្រោងសាងសង់អនុស្ថានីយអគ្គិសនី | | (គ្រប់ទំហំ) | |
| ៣៩ | បណ្តាញខ្សែបញ្ជូនថាមពលអគ្គិសនី | (>២៣០គីឡូវ៉ុល) | (≥១១៥–២៣០ គីឡូវ៉ុល) | (<១១៥គីឡូវ៉ុល) |
| ៤០ | រោងចក្រផលិត ផ្គុំដំឡើងបន្ទះសូឡា | | (គ្រប់ទំហំ) | |
| ៤១ | រោងចក្រផលិតអំពូលភ្លើងគ្រប់ប្រភេទ | | (គ្រប់ទំហំ) | |
| ៤២ | រោងចក្រផ្គុំដំឡើងសម្ភារៈបរិក្ខារអគ្គិសនី និងអេឡិចត្រូនិចគ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ៤៣ | ស្ថានីយបញ្ចូលថាមពលយានយន្តអគ្គិសនី (ដែលមានលក្ខណៈសេវាកម្ម ឬអាជីវកម្ម) | | | (គ្រប់ទំហំ) |
| ៤៤ | រោងចក្រផលិតគ្រឿងបង្គុំខ្សែភ្លើង អេឡិចត្រូនិកសម្រាប់រថយន្ត | | (គ្រប់ទំហំ) | |
| ៤៥ | រោងចក្រផលិត និងផ្គុំដំឡើងឧបករណ៍បញ្ចូលភ្លើងកុំព្យូទ័រ ឧបករណ៍បំពងសំឡេង និងទូរស័ព្ទ | | (គ្រប់ទំហំ) | |
| ៤៦ | រោងចក្រផលិត ផ្គុំដំឡើងនាឡិកាដៃ នាឡិកាព្យួរជញ្ជាំងគ្រប់ប្រភេទ | | (គ្រប់ទំហំ) | |
| ៤៧ | រោងចក្រផលិតវ៉ែនតា និងគ្រឿងបន្សំវ៉ែនតាគ្រប់ប្រភេទ | | (គ្រប់ទំហំ) | |
| ៤៨ | រោងចក្រផលិតសំបកកង់រថយន្តគ្រប់ប្រភេទ | | (គ្រប់ទំហំ) | |
| ៤៩ | រោងចក្រផលិតសំបកកង់ម៉ូតូ សំបកកង់ ពោះវៀនម៉ូតូ ពោះវៀនកង់គ្រប់ប្រភេទ | | (≥៥០០តោន/ឆ្នាំ) | (<៥០០តោន/ឆ្នាំ) |

| | | | | |
|---|---|---|---|---|
| ៥០ | រោងចក្រផលិតគ្រឿងយន្ត | | (គ្រប់ទំហំ) | |
| ៥១ | រោងចក្រផលិតគ្រឿងបង្គុំ គ្រឿងបន្លាស់ សម្រាប់យានយន្តនិងគ្រឿងចក្រគ្រប់ប្រភេទ | | (គ្រប់ទំហំ) | |
| ៥២ | រោងចក្រផលិតស្បែកហ្វ្រាំងឡាន និង/ឬហ្វ្រាំងទោចក្រយានយន្ត ត្រីចក្រយានយន្ត | | (គ្រប់ទំហំ) | |
| ៥៣ | រោងចក្រផលិត និងផ្គុំដំឡើងរថយន្តគ្រប់ប្រភេទ | | (គ្រប់ទំហំ) | |
| ៥៤ | រោងចក្រផលិត និងផ្គុំដំឡើងគ្រឿងម៉ាស៊ីន សម្ភារៈបរិក្ខារឧស្សាហកម្ម និងមុខសញ្ញាពាក់ព័ន្ធផ្សេងទៀត | | (គ្រប់ទំហំ) | |
| ៥៥ | រោងចក្រដំឡើងឧបករណ៍លើកដាក់ទំនិញ | | | (គ្រប់ទំហំ) |
| ៥៦ | រោងចក្រប្លាស្ទិក | | (គ្រប់ទំហំ) | |
| ៥៧ | រោងចក្រកិនជ័រ និងផលិតគ្រាប់ជ័រ | | (គ្រប់ទំហំ) | |
| ៥៨ | រោងចក្រផលិតកញ្ចក់ | | (គ្រប់ទំហំ) | |
| ៥៩ | រោងចក្រកែច្នៃកម្ទេចប្លាស្ទិក និងផលិតផលពីប្លាស្ទិក | | (គ្រប់ទំហំ) | |
| ៦០ | រោងចក្រកៅស៊ូក្រេប/កែច្នៃកៅស៊ូ | | (≥១ ០០០តោន/ឆ្នាំ) | (<១ ០០០តោន/ឆ្នាំ) |
| ៦១ | រោងចក្រផលិតអេប៉ុង កៅស៊ូមូស | | (គ្រប់ទំហំ) | |
| ៦២ | រោងចក្រផលិតថ្នាំសម្លាប់សត្វល្អិត ឬថ្នាំកសិកម្មគ្រប់ប្រភេទ | | (គ្រប់ទំហំ) | |
| ៦៣ | រោងចក្រផលិតម្សៅសាប៊ូ សាប៊ូដុំ សាប៊ូទឹក | | (គ្រប់ទំហំ) | |
| ៦៤ | រោងចក្រកែច្នៃសំណល់ ដុតសំណល់ | | (គ្រប់ទំហំ) | |
| ៦៥ | សហគ្រាសអាជីវកម្មប្រមូលទិញ ស្តុក និងកែច្នៃសំណល់សំបកកង់យានយន្តគ្រប់ប្រភេទ | | (គ្រប់ទំហំ) | |
| ៦៦ | រោងចក្រតម្បាញ ជ្រលក់ពណ៌ | | (គ្រប់ទំហំ) | |
| ៦៧ | រោងចក្រកាត់ដេរ បោកគក់ បោះពុម្ព | | (គ្រប់ទំហំ) | |
| ៦៨ | រោងចក្រកាត់ដេរសម្លៀកបំពាក់ ធ្វើពីរោមសត្វ ស្បែកសត្វ កែច្នៃរោមសត្វ និងស្បែកជាប់រោមសត្វ | | (គ្រប់ទំហំ) | |
| ៦៩ | រោងចក្រផលិតកាំជ្រួច សារធាតុផ្ទុះ | (គ្រប់ទំហំ) | | |
| ៧០ | រោងចក្រចម្រាញ់ដូងប្រេង | | (គ្រប់ទំហំ) | |
| ៧១ | រោងចក្រផលិតសំបកកំប៉ុងពីអាលុយមីញ៉ូម | | (គ្រប់ទំហំ) | |
| ៧២ | រោងចក្របិញ្ចាំដើមអាកាស្យា ដើមប្រេងខ្យល់ ដើមកៅស៊ូ និងដើមឈើដាំផ្សេងៗ | | (គ្រប់ទំហំ) | |
| ៧៣ | រោងចក្រផលិតកែវ ដបគ្រប់ប្រភេទ | | (គ្រប់ទំហំ) | |
| ៧៤ | សហគ្រាស ឬរោងចក្រផលិតឥដ្ឋក្រាល ឥដ្ឋការ៉ូ | | (គ្រប់ទំហំ) | |
| ៧៥ | សហគ្រាស ឬរោងចក្រផលិតឥដ្ឋ ក្បឿងគ្រប់ប្រភេទ | | ≥១៥០ ០០០ដុំ/ខែ | <១៥០ ០០០ដុំ/ខែ |
| ៧៦ | សហគ្រាស ឬរោងចក្រលាយបេតុង | | (>៣០ ០០០ ម៉ែត្រគុប/ខែ) | (≤៣០ ០០០ ម៉ែត្រគុប/ខែ) |
| ៧៧ | សហគ្រាស ឬរោងចក្រផលិតលូ និងគ្រឿងសំណង់បេតុង | | (>៣០ ០០០ ម៉ែត្រគុប/ខែ) | (≤៣០ ០០០ ម៉ែត្រគុប/ខែ) |
| ៧៨ | រោងចក្រផលិតសសរគ្រឹះ និងបង្គោលភ្លើង | | | (គ្រប់ទំហំ) |

| | | | | |
|---|---|---|---|---|
| ៧៩ | រោងចក្រផលិតសម្ភារៈបរិក្ខារបម្រើឱ្យវិស័យសំណង់ | | | (គ្រប់ទំហំ) |
| ៨០ | រោងចក្រផលិតទ្វារ និងកញ្ចក់ក្បាច់ | | | (គ្រប់ទំហំ) |
| ៨១ | រោងចក្រផលិតបន្ទះកម្រាល បន្ទះជញ្ជាំង បន្ទះហ្វីប្រូ និងក្បឿង | | | (គ្រប់ទំហំ) |
| ៨២ | រោងចក្រផលិតសង្កសី ទ្វាររមូរ និងដែកសំណង់ | | | (គ្រប់ទំហំ) |
| ៨៣ | រោងចក្រផលិតធ្យូង (ចេញពីកាកអំពៅ គ្រឡោកដូង អង្កាម ដើមឫស្សី ឬសមាសភាពសរីរាង្គផ្សេងៗ) | | (គ្រប់ទំហំ) | |
| ៨៤ | រោងចក្រផលិត និងកែច្នៃអំបិល | | (≥៣ ០០០តោន/ឆ្នាំ) | (<៣ ០០០តោន/ឆ្នាំ) |
| ៨៥ | រោងចក្រផលិតស្ករស | | (≥៣ ០០០តោន/ឆ្នាំ) | (<៣ ០០០តោន/ឆ្នាំ) |
| ៨៦ | រោងចក្រក្តារបន្ទះ | | (≥១០០ ០០០ម៉ែត្រគូប/ឆ្នាំ ឈើមូល) | (<១០០ ០០០ ម៉ែត្រគូប/ឆ្នាំ ឈើមូល) |
| ៨៧ | រោងចក្រផលិតក្តារបន្ទះគ្រប់ប្រភេទពីកម្ទេចឈើ ឬឈើកិនសម្បនិម្មិត | | (គ្រប់ទំហំ) | |
| ៨៨ | រោងចក្រអារឈើ | | (≥៥០ ០០០ម៉ែត្រគូប/ឆ្នាំ ឈើមូល) | (<៥០ ០០០ម៉ែត្រគូប/ឆ្នាំ ឈើមូល) |
| ៨៩ | រោងចក្រកែច្នៃថ្មអារ ថ្មម៉ាប ថ្មកក់ និងថ្មគ្រប់ប្រភេទ | | (គ្រប់ទំហំ) | |
| ៩០ | រោងចក្រផលិតគ្រឿងសង្ហារិមគ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ៩១ | រោងចក្រកែច្នៃផលិតផលពីដើមឫស្សី | | | (គ្រប់ទំហំ) |
| ៩២ | រោងចក្រផលិតម្សៅមី | | (គ្រប់ទំហំ) | |
| ៩៣ | រោងចក្រកែច្នៃដំឡូងមី និងកែច្នៃផលិតផលផ្សេងៗ | | (គ្រប់ទំហំ) | |
| ៩៤ | រោងចក្រផលិតចំណីសត្វ | | (≥១០ ០០០តោន/ឆ្នាំ) | (<១០ ០០០តោន/ឆ្នាំ) |
| ៩៥ | រោងចក្រ ឬម៉ាស៊ីនកិនស្រូវ និងគ្រាប់ធញ្ញជាតិ / រោងចក្រកែច្នៃស្រូវ និងគ្រាប់ធញ្ញជាតិ | | | (≥៣ ០០០តោន/ឆ្នាំ) |
| ៩៦ | រោងចក្រផលិតទឹកត្រី ស៊ីអ៊ីវ សៀង ម្ទេស ប៉េងប៉ោះ | | | (≥៥០០ ០០០ លីត្រ/ឆ្នាំ) |
| ៩៧ | រោងចក្រផលិតនំបញ្ចុក គុយទាវ និងមីកញ្ចប់ គ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ៩៨ | រោងចក្រកែច្នៃ/ផលិតម្ហូបអាហារ និងគ្រឿងកំប៉ុង | | (≥៥០០តោន/ឆ្នាំ) | (<៥០០តោន/ឆ្នាំ) |
| ៩៩ | រោងចក្រផលិត កែច្នៃនំដុត នំក្រៀម នំប៊ីស្គីត នំប៉ាស្រ្ទី និងនំគ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ១០០ | រោងចក្រផលិតភេសជ្ជៈ ទឹកផ្លែឈើគ្រប់ប្រភេទ | | (គ្រប់ទំហំ) | |
| ១០១ | រោងចក្រផលិត កែច្នៃការ៉េម ការ៉េមប្រអប់ ការ៉េមដើម ឬទឹកកកសជាតិដ៏ទៃទៀត | | | (គ្រប់ទំហំ) |
| ១០២ | រោងចក្រផលិត កែច្នៃកាកាវ សូកូឡា | | | (គ្រប់ទំហំ) |
| ១០៣ | រោងចក្រផលិតតំណាប់ផ្លែឈើ និង/ឬ កែច្នៃផ្លែឈើ | | (≥៥០០តោន/ឆ្នាំ) | (<៥០០តោន/ឆ្នាំ) |
| ១០៤ | រោងចក្រសម្ងួតគ្រាប់ធញ្ញជាតិ | | | (គ្រប់ទំហំ) |
| ១០៥ | រោងចក្រផលិតទឹកតែត្រជាក់ និងផលិតផលពីទឹកដោះសត្វ | | | (គ្រប់ទំហំ) |
| ១០៦ | រោងចក្រកែច្នៃ/ផលិតម្សៅអង្ករ | | | (គ្រប់ទំហំ) |

| | | | | |
|---|---|---|---|---|
| ១០៧ | ស្ថានីយផលិតទឹកស្អាតប្រើប្រាស់ និងប្រព័ន្ធចែកចាយ | | | (គ្រប់ទំហំ) |
| ១០៨ | រោងចក្រផលិតទឹកសុទ្ធ | | | (គ្រប់ទំហំ) |
| ១០៩ | រោងចក្រផលិតទឹកកក | | | (គ្រប់ទំហំ) |
| ១១០ | រោងចក្រផលិត ផ្គុំដំឡើងគ្រឿងយន្ត រថយន្ត ត្រីចក្រយានយន្ត ទោចក្រយានយន្ត | | (គ្រប់ទំហំ) | |
| ១១១ | រោងចក្រផ្គុំឬដំឡើងយន្តហោះ យានអាវកាស ម៉ាស៊ីន ឬគ្រឿងបន្លាស់ដែលពាក់ព័ន្ធដ៏ទៃទៀត | (គ្រប់ទំហំ) | | |
| ១១២ | រោងចក្រផ្គុំឬដំឡើងក្បាលរថភ្លើង ទូផ្ទុកទំនិញ និងនាវា ឬគ្រឿងបន្លាស់ដែលពាក់ព័ន្ធដ៏ទៃទៀត | (គ្រប់ទំហំ) | | |
| ១១៣ | រោងចក្រផ្គុំដំឡើងទោចក្រយាន រ៉ឺម៉ក ត្រីចក្រយាន ទោចក្រយានយន្តអគ្គិសនី ត្រីចក្រយានយន្ត-អគ្គិសនី | | | (គ្រប់ទំហំ) |
| ១១៤ | សហគ្រាសជួសជុលគ្រឿងយន្ត និងនាវា | | | (គ្រប់ទំហំ) |
| ១១៥ | រោងចក្រផលិតបំពង់ទីប | | | (គ្រប់ទំហំ) |
| ១១៦ | រោងចក្រផលិតគ្រឿងបង្គុំសម្រាប់គ្រឿងសង្ហារិម (ពីដែក ឬឈើកិន ឬលោហៈពាក់កណ្ដាលសម្រេច) | | | (គ្រប់ទំហំ) |
| ១១៧ | រោងចក្រផលិត និងផ្គុំដំឡើងឧបករណ៍ជាងគ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ១១៨ | រោងចក្រផ្គុំដំឡើងគ្រឿងសម្ភារៈសិប្បនិម្មិតសម្រាប់លម្អគ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ១១៩ | រោងចក្រផលិតស្រោមដៃ ស្រោមជើង កន្សែង ភួយ មួក ម៉ាស់ | | | (គ្រប់ទំហំ) |
| ១២០ | រោងចក្រផលិតសម្ភារៈប្រើប្រាស់ក្នុងផ្ទះបាយ និងផលិតផល សម្រាប់បិទលម្អគ្រឿងសង្ហារិម (ពីក្រដាស ក្រណាត់ ក្រណាត់ប្លាស្ទិក ក្រណាត់ស្បែក ដុំ/បន្ទះប្លាស្ទិក) | | | (គ្រប់ទំហំ) |
| ១២១ | រោងចក្រផលិតវត្ថុអនុស្សាវរីយ៍គ្រប់ប្រភេទ (ពីក្រដាស ក្រណាត់ ក្រណាត់ប្លាស្ទិក ក្រណាត់ស្បែក ដុំ/បន្ទះប្លាស្ទិក) | | | (គ្រប់ទំហំ) |
| ១២២ | រោងចក្រផ្គុំដំឡើងគ្រឿងសម្ភារៈសិប្បនិម្មិតសម្រាប់លម្អគ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ១២៣ | រោងចក្រផលិតសម្ភារៈ ក្រដាស សំឡី ខោ ក្រណាត់អនាម័យគ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ១២៤ | រោងចក្រផលិតសម្ភារៈបោះដំរុំ ឆ័ត្រ តង់ គ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ១២៥ | រោងចក្រផ្គុំដំឡើងទូកកាយ៉ាក់ (ពីក្រណាត់ប្លាស្ទិក ក្រណាត់ ក្រណាត់ស្បែក) | | | (គ្រប់ទំហំ) |
| ១២៦ | រោងចក្រផលិតស្ករគ្រាប់ | | | (គ្រប់ទំហំ) |
| ១២៧ | រោងចក្រផលិតតុក្កតា ប្រដាប់ក្មេងលេង គ្រប់ប្រភេទ (ពីក្រណាត់ ឬក្រណាត់ស្បែក) | | | (គ្រប់ទំហំ) |

| | | | | |
|---|---|---|---|---|
| ១២៨ | រោងចក្រផលិតសម្ភារៈវេចខ្ចប់គ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ១២៩ | រោងចក្រផលិតប្រអប់ ថង់ក្លាសេ (ពីក្រណាត់ ឬក្រណាត់ស្បែក) | | | (គ្រប់ទំហំ) |
| ១៣០ | រោងចក្រផលិតខ្សែឃឹតចង្កេះខោសម្រាប់ផ្គត់ផ្គង់ | | | (គ្រប់ទំហំ) |
| ១៣១ | រោងចក្រផលិតកេសកាតុង | | | (គ្រប់ទំហំ) |
| ១៣២ | រោងចក្រផលិតអំបោះ ខារអំបោះដេរ ផលិតសូតបិត | | | (គ្រប់ទំហំ) |
| ១៣៣ | រោងចក្រផលិតសក់សិប្បនិម្មិត | | | (គ្រប់ទំហំ) |
| ១៣៤ | រោងចក្រផលិតសម្ភារៈការិយាល័យគ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ១៣៥ | រោងចក្រផលិតសម្ភារៈសួចត្រីគ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ១៣៦ | រោងចក្រផលិតទ្រនាប់កាត់ពុម្ពស្បែកជើង | | | (គ្រប់ទំហំ) |
| ១៣៧ | រោងចក្រផលិតអាវភ្លៀងគ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ១៣៨ | រោងចក្រផលិតរនាំងស្លាបព្រិល និងរបាំងបង្អួចគ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ១៣៩ | សហគ្រាស ឬរោងចក្រផលិតរានទេវតាពីឈើនាំចូល និងឈើដាំក្នុងស្រុក | | | (គ្រប់ទំហំ) |
| ១៤០ | សហគ្រាស ឬរោងចក្រផលិតទៀន | | | (គ្រប់ទំហំ) |
| ១៤១ | សហគ្រាស ឬរោងចក្រផលិតបារ | | | (គ្រប់ទំហំ) |
| ១៤២ | រោងចក្រផលិតសម្ភារៈ គ្រឿងសម្រាប់តុបតែង និងបំពាក់រថយន្ត | | | (គ្រប់ទំហំ) |
| ១៤៣ | រោងចក្រផលិតស្រោមកែវ ស្រោមដប | | | (គ្រប់ទំហំ) |
| ១៤៤ | រោងចក្រផលិតគ្រឿងសម្ភារៈថែរក្សាសម្ផស្ស | | | (គ្រប់ទំហំ) |
| ១៤៥ | រោងចក្រផលិតប្រដាប់ព្យួរសម្លៀកបំពាក់គ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ១៤៦ | រោងចក្រផលិតសម្ភារៈកីឡាគ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ១៤៧ | រោងចក្រផលិតពូក ខ្នើយ | | | (គ្រប់ទំហំ) |
| ១៤៨ | រោងចក្រផ្គុំដំឡើងសម្ភារៈប្រើប្រាស់ក្នុងផ្ទះបាយ ចង្ក្រានអាំងសាច់ ឆ្នើរ ទូដាក់ចានឆ្នាំង និងសម្ភារៈផ្សេងទៀត | | | (គ្រប់ទំហំ) |
| ១៤៩ | រោងចក្រកាត់ដេរសម្លៀកបំពាក់ និងសម្ភារៈប្រើប្រាស់សម្រាប់សត្វចិញ្ចឹមគ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ១៥០ | សហគ្រាស ឬរោងចក្រផលិតចាន ឆ្នាំង ប៉ាន់តែ ពែង និងសម្ភារៈផ្សេងៗ | | | (គ្រប់ទំហំ) |
| ១៥១ | រោងចក្រផលិតខ្សែក្រវ៉ាត់គ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ១៥២ | រោងចក្រកម្រាលតុ កម្រាលពូក និងស្រោមខ្នើយ | | | (គ្រប់ទំហំ) |
| ១៥៣ | រោងចក្រផលិតឡេវ ខ្សែរូតគ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ១៥៤ | រោងចក្រផលិតកាបូបគ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ១៥៥ | រោងចក្រផលិតស្បែកជើង | | | (គ្រប់ទំហំ) |
| ១៥៦ | រោងចក្រផលិតគ្រឿងបន្សំស្បែកជើង | | | (គ្រប់ទំហំ) |
| ១៥៧ | រោងចក្រកាត់ដេរសម្លៀកបំពាក់ | | | (គ្រប់ទំហំ) |
| ១៥៨ | រោងចក្រផលិតគ្រឿងបន្សំសម្លៀកបំពាក់ | | | (គ្រប់ទំហំ) |

| | | | | |
|---|---|---|---|---|
| ១៥៩ | រោងចក្រផលិតស្លាកសញ្ញាសម្លៀកបំពាក់ | | | (គ្រប់ទំហំ) |
| ១៦០ | រោងចក្រកផលិតគ្រឿងបន្សំកាបូបគ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ១៦១ | រោងចក្រផលិត និងផ្គុំដំឡើងពិលគ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ១៦២ | រោងចក្រផលិតគ្រឿងបន្សំខ្សែក្រវ៉ាត់គ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| **២. វិស័យសុខាភិបាល** | | | | |
| ១៦៣ | មន្ទីរពេទ្យ | (គ្រប់ទំហំ) | | |
| ១៦៤ | មន្ទីរពេទ្យបង្អែក | | (គ្រប់ទំហំ) | |
| ១៦៥ | មន្ទីរពិសោធន៍ | | (គ្រប់ទំហំ) | |
| ១៦៦ | មណ្ឌលលាងឈាម | | (គ្រប់ទំហំ) | |
| ១៦៧ | មន្ទីរ ឬបន្ទប់ពិគ្រោះ និងព្យាបាលជំងឺ | | | (គ្រប់ទំហំ) |
| ១៦៨ | រោងចក្រផលិតម៉ាស៊ីន/សម្ភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ | | (គ្រប់ទំហំ) | |
| ១៦៩ | រោងចក្រ ឬសិប្បកម្មផលិតឱសថ | | (គ្រប់ទំហំ) | |
| ១៧០ | រោងចក្រផលិតវត្ថុធាតុដើមសម្រាប់ផលិតឱសថ | | (គ្រប់ទំហំ) | |
| ១៧១ | រោងចក្រផ្គុំដំឡើងម៉ាស៊ីន ឧបករណ៍សម្ភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ១៧២ | រោងចក្រផលិត សម្ភារៈបរិក្ខារពេទ្យដែលធ្វើពីក្រណាត់ ឬសរសៃអំបោះ (សម្លៀកបំពាក់ ឬក្រណាត់ មួក ម៉ាស់ បង់រុំ ឬសំឡី ដែលប្រើប្រាស់ក្នុងវិស័យសុខាភិបាល) | | | (គ្រប់ទំហំ) |
| ១៧៣ | មន្ទីរពហុព្យាបាល មន្ទីរព្យាបាល សម្ភព | | | (គ្រប់ទំហំ) |
| ១៧៤ | មណ្ឌលសុខភាព | | | (គ្រប់ទំហំ) |
| ១៧៥ | ឃ្លាំងស្តុកឱសថ | | | (គ្រប់ទំហំ) |
| **៣. វិស័យធនធានទឹក** | | | | |
| ១៧៦ | ប្រព័ន្ធស្រោចស្រព | | (≥៥ ០០០ហិកតា) | (១០០០-<៥ ០០០ ហិកតា) |
| ១៧៧ | ប្រព័ន្ធដោះទឹក | | (≥៥ ០០០ហិកតា) | (១០០០-<៥០០០ ហិកតា) |
| ១៧៨ | សំណង់ទំនប់ទឹក ទំនប់ស្ទាក់ទឹក អាងស្តុកទឹក | > ២០០ហិកតា | (≥ ១០-២០០ហិកតា) | |
| **៤. វិស័យកសិកម្ម** | | | | |
| ១៧៩ | ផ្ទៃដីលិចទឹក និងដីតំបន់ឆ្នេរ | (គ្រប់ទំហំ) | | |
| ១៨០ | អាជីវកម្មព្រៃគប់ | (≥៥០០ហិកតា) | | (<៥០០ហិកតា) |
| ១៨១ | ផ្ទៃដីដែលមានព្រៃឈើ | (≥៥០០ហិកតា) | | (<៥០០ហិកតា) |
| ១៨២ | ផ្ទៃដីដំណាំកសិកម្ម ឧស្សាហកម្ម | (≥៥០០ហិកតា) | | (<៥០០ហិកតា) |
| ១៨៣ | ព្រៃសម្បទាន | (≥៥០០ហិកតា) | | (<៥០០ហិកតា) |
| ១៨៤ | កសិដ្ឋានដាំដំណាំក្នុងផ្ទះសំណាញ់ | | | (គ្រប់ទំហំ) |
| ១៨៥ | ផែនេសាទ លើកលែងចំពោះផែនេសាទលក្ខណៈគ្រួសារ | | (គ្រប់ទំហំ) | |
| ១៨៦ | កសិដ្ឋានចិញ្ចឹមសត្វមាន់ ទា និងប្រភេទបក្សីចិញ្ចឹមយកសាច់ និង/ឬស៊ុត ផ្សេងៗទៀត | | (≥៥០ ០០០ក្បាល) | (២ ០០០-<៥០ ០០០ ក្បាល) |

| | | | | |
|---|---|---|---|---|
| ១៨៧ | កសិដ្ឋានចិញ្ចឹមសត្វគោ ក្របី ជ្រូក ចៀម ពពែ សេះ ស្វា ទោច ទន្សាយ និងសត្វចិញ្ចឹមយកសាច់ និង/ឬទឹកដោះ ផ្សេងៗទៀត | | (≥៥០០ក្បាល) | (១០០-<៥០០ក្បាល) |
| ១៨៨ | កសិដ្ឋានចិញ្ចឹមសត្វក្រពើ អណ្តើក កន្ធាយ | | (≥៥០០ក្បាល) | (១០០-<៥០០ក្បាល) |
| ១៨៩ | កសិដ្ឋានចិញ្ចឹមសត្វលូន | | (≥៥០ ០០០ក្បាល) | (២ ០០០- ៥០ ០០០ ក្បាល) |
| ១៩០ | កសិដ្ឋានចិញ្ចឹមសត្វល្អិត | | | (គ្រប់ទំហំ) |
| ១៩១ | អាជីវកម្មផ្ទះចិញ្ចឹមសត្វត្រចៀកកាំ | | | (គ្រប់ទំហំ) |
| ១៩២ | វារីវប្បកម្មចិញ្ចឹមត្រី ក្តាម បង្គា បង្កង និងវារីវប្បកម្មផ្សេងៗទៀត | | (≥១០ហិកតា) | (៥-<១០ហិកតា) |
| ១៩៣ | វារីវប្បកម្មដាំសារាយ ផ្កាថ្ម និងស្មៅសមុទ្រ | | (≥២០ហិកតា) | (៥-<២០ហិកតា) |
| ១៩៤ | ស្តារ និងអភិវឌ្ឍន៍ដំណាំកសិកម្ម ឧស្សាហកម្ម | | (≥៥០០ហិកតា) | (<៥០០ហិកតា) |
| ១៩៥ | ទីសត្តឃាត | | (≥១០០ក្បាល/ថ្ងៃ) | (១០-<១០០ ក្បាល/ថ្ងៃ) |
| ១៩៦ | ឃ្លាំងស្តុក និងលក់ ថ្នាំ ឬជីកសិកម្ម | | | (≥១០ ០០០ តោន/ឆ្នាំ) |
| **៥. វិស័យទេសចរណ៍** | | | | |
| ១៩៧ | តំបន់ទេសចរណ៍ | (>៥០ហិកតា) | (>១០-៥០ហិកតា) | (≤១០ហិកតា) |
| ១៩៨ | អាជីវកម្មខារ៉ាអូខេ រង្គសាល និងឌីស្កូតែក | (ផ្ទៃក្រឡាសំណង់ > ៤៥ ០០០ម៉ែត្រការ៉េ) | (ផ្ទៃក្រឡាសំណង់ > ១៥ ០០០-៤៥ ០០០ ម៉ែត្រការ៉េ) | (ផ្ទៃក្រឡាសំណង់ > ៣ ០០០-១៥ ០០០ ម៉ែត្រការ៉េ) |
| ១៩៩ | ទីលានវាយកូនគោល | | (≥១៨រន្ធ) | (<១៨រន្ធ) |
| ២០០ | បង្កើតសួនសត្វ | | (≥១០ហិកតា) | (<១០ហិកតា) |
| ២០១ | ភោជនីយដ្ឋាន | | (>៥០០កៅអី) | (>១០០-៥០០ កៅអី) |
| ២០២ | កំពង់ផែទេសចរណ៍ | | (គ្រប់ទំហំ) | |
| ២០៣ | សេវាកម្មទូកទេសចរណ៍ | | | (គ្រប់ទំហំ) |
| ២០៤ | ភោជនីយដ្ឋានបណ្តែតទឹក | | | (≥៣០០កៅអី) |
| ២០៥ | បៀរហ្គាដេន | | | (គ្រប់ទំហំ) |
| ២០៦ | អាហារដ្ឋានទេសចរណ៍ | | | (≥៣០០កៅអី) |
| **៦. វិស័យហេដ្ឋារចនាសម្ព័ន្ធ** | | | | |
| ២០៧ | សំណង់អាកាសយានដ្ឋាន | (គ្រប់ទំហំ) | | |
| ២០៨ | ការអភិវឌ្ឍទីក្រុង | (គ្រប់ទំហំ) | | |
| ២០៩ | ការសាងសង់ពហុកីឡាដ្ឋាន | (គ្រប់ទំហំ) | | |
| ២១០ | ទីលានទុកដាក់សំណល់ឧស្សាហកម្ម សំណល់គ្រោះថ្នាក់ | (គ្រប់ទំហំ) | | |
| ២១១ | ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន | | (គ្រប់ទំហំ) | |

| | | | | |
|---|---|---|---|---|
| ២១២ | តំបន់សួនឧស្សាហកម្ម/តំបន់សេដ្ឋកិច្ចពិសេស/ តំបន់ប្រមូលផ្តុំសហគ្រាសធុនតូច និងមធ្យម | (គ្រប់ទំហំ) | | |
| ២១៣ | ស្ថានីយអាងប្រព្រឹត្តកម្មបែបយន្តកម្ម និងប្រព័ន្ធបណ្តាញលូ | | (គ្រប់ទំហំ) | |
| ២១៤ | ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់រួម និងប្រព័ន្ធបណ្តាញលូ | (គ្រប់ទំហំ) | | |
| ២១៥ | សំណង់ផ្លូវដែក | (គ្រប់ទំហំ) | | |
| ២១៦ | សំណង់កំពង់ផែ លើកលែងតែសំណង់កំពង់ផែជាលក្ខណៈគ្រួសារ | (គ្រប់ទំហំ) | | |
| ២១៧ | ផែស្ងួត | | (គ្រប់ទំហំ) | |
| ២១៨ | ស្ថាបនា និងប្រតិបត្តិការខ្សែកាបក្រោមបាតសមុទ្រ និងហេដ្ឋារចនាសម្ព័ន្ធ រាប់បញ្ចូលទាំងការភ្ជាប់ខ្សែកាបពីសមុទ្រ ឡើងគោក | (គ្រប់ទំហំ) | | |
| ២១៩ | សំណង់អគារគ្រប់ប្រភេទ (សំណង់អគារការិយាល័យ សំណង់អគារពហុវិស័យ សំណង់អគារពាណិជ្ជកម្ម សំណង់អគារខុនដូ សំណង់បុរី សំណង់ផ្ទះល្វែងនិងវីឡា សំណង់អគារផ្សារទំនើប និងសំណង់អគារផ្សេងៗ) | (ផ្ទៃក្រឡាសំណង់ >៤៥ ០០០ម៉ែត្រការ៉េ) | (ផ្ទៃក្រឡាសំណង់ >១៥ ០០០- ៤៥ ០០០ ម៉ែត្រការ៉េ) | (ផ្ទៃក្រឡាសំណង់ >៣ ០០០-១៥ ០០០ ម៉ែត្រការ៉េ) |
| ២២០ | សំណង់សណ្ឋាគារតំបន់ឆ្នេរ/មាត់ទន្លេ | (>២៣០បន្ទប់) | (≥៦០-២៣០បន្ទប់) | (<៦០បន្ទប់) |
| ២២១ | សំណង់សណ្ឋាគារក្រៅពីតំបន់ឆ្នេរ និងមាត់ទន្លេ | (>២៥០បន្ទប់) | (≥៨០-២៥០បន្ទប់) | (<៨០បន្ទប់) |
| ២២២ | សំណង់ផ្លូវថ្នល់ | (>១០០គ.ម) | (≥៣០ -១០០គ.ម) | (១០-<៣០គ.ម) |
| ២២៣ | សំណង់ពង្រីកផ្លូវថ្នល់ ផ្លូវដែក | (>១០០គ.ម) | (≥៥០-១០០គ.ម) | (១០-<៥០គ.ម) |
| ២២៤ | សំណង់ផ្លូវនៅក្នុងតំបន់ការពារធម្មជាតិ | (>៣០គ.ម) | (≥១០-៣០គ.ម) | (<១០គ.ម) |
| ២២៥ | សំណង់ជួសជុល ពង្រីកផ្លូវនៅក្នុងតំបន់ការពារធម្មជាតិ | (>៥០គ.ម) | (≥១០-៥០គ.ម) | (<១០គ.ម) |
| ២២៦ | ការបូមភក់ ល្បាប់ | (≥៥០ ០០០ម៉ែត្រគុប) | | (<៥០០០០ម៉ែត្រគុប) |
| ២២៧ | ការចាក់បំពេញទីតាំងគម្រោងអភិវឌ្ឍន៍ | ( > ១០០ ហិកតា) | (>៥០–១០០ហិកតា) | (≥១០-៥០ហិកតា) |
| ២២៨ | សំណង់ផ្ទះសំណាក់ | | (≥៨០បន្ទប់) | (<៨០បន្ទប់) |
| ២២៩ | នាវាចរណ៍ | | (≥១០០តោន) | (<១០០តោន) |
| ២៣០ | សំណង់ស្ពានថ្នល់ | | (ទម្ងន់≥៣០តោន) | |
| ២៣១ | បណ្តាញបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន | | (គ្រប់ទំហំ) | |
| ២៣២ | បណ្តាញខ្សែកាបអុបទិកលើគោក | | (គ្រប់ទំហំ) | |
| ២៣៣ | មជ្ឈមណ្ឌលទិន្នន័យ | | (គ្រប់ទំហំ) | |
| ២៣៤ | មជ្ឈមណ្ឌលពិសោធន៍ រួមមានការត្រួតពិនិត្យគុណភាព បច្ចេកទេស និងការបញ្ជាក់វិញ្ញាបនបត្រ | | (គ្រប់ទំហំ) | |

| | | | | |
|---|---|---|---|---|
| ២៣៥ | សេវាទូរគមនាគមន៍មូលដ្ឋាន (ទូរស័ព្ទចល័ត ទូរស័ព្ទអចល័ត អ៊ីនធើណេត និងសេវាផ្តល់អត្ថប្រយោជន៍បន្ថែម) | | | (គ្រប់ទំហំ) |
| ២៣៦ | គម្រោងសាងសង់ស្តង់-តូប និងផ្សារមេឃ | | | (គ្រប់ទំហំ) |
| ២៣៧ | ទីតាំងដំឡើងប្រព័ន្ធទូរស័ព្ទ | | | (គ្រប់ទំហំ) |
| ២៣៨ | ទីលានបញ្ចុះសព | | | (≥៥ហិកតា) |

***សម្គាល់៖***

- វ.ហ.ប.ព ៖ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ
- វ.ហ.ប.ដ៖ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង